**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

លេខ: 20 PR-25/EoJ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥

## ការចាប់ផ្តើមទទួលពាក្យសុំចូលរួម
## ការប្រឡងចម្រៀងណូដូជីម៉ាន់២០២៥

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនថា ស្ថានទូត រួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) ការិយាល័យទំនាក់ទំនងភ្នំពេញនៃមូលនិធិជប៉ុន នឹងរៀបចំនូវការប្រឡងចម្រៀងណូដូជីម៉ាន់២០២៥ (ការប្រឡងចម្រៀងភាសាជប៉ុន) នៅថ្ងៃអាទិត្យ ទី១៣ ខែកក្កដា ឆ្នាំ២០២៥ នៅCJCC ក្នុងឱកាសពិធីបុណ្យផ្កាយ (តាណាបាតា) ២០២៥ ផងដែរ។

ការប្រឡងចម្រៀងណូដូជីម៉ាន់(ចម្រៀងភាសាជប៉ុន) ត្រូវបានប្រារព្ធឡើងក្នុងគោលបំណងលើកទឹកចិត្តអ្នកសិក្សាភាសាជប៉ុនបានអនុវត្តការបញ្ចេញសំឡេងជាភាសាជប៉ុន។ លើសពីនេះទៀត ការប្រឡងនេះក៏មានគោលបំណងពង្រឹងចំណងមិត្តភាព និងការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រជាជនជប៉ុន និងកម្ពុជា តាមរយៈចម្រៀងភាសាជប៉ុនផងដែរ។

យើងខ្ញុំ សូមស្វាគមន៍ប្រជាជនកម្ពុជាគ្រប់រូបដែលចូលចិត្តច្រៀងចម្រៀងភាសាជប៉ុន ចូលរួមប្រឡងចម្រៀងនេះ តាមរយៈ Microsoft Form ដែលមានភ្ជាប់ (https://forms.office.com/r/4GMt7CnDQW)។ ផុតកំណត់ការដាក់ពាក្យត្រឹមថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២២) ឬផ្ញើអ៊ីម៉េលមកកាន់អាសយដ្ឋាន៖ info.jpn@pp.mofa.go.jp ។

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Email: info.jpn@pp.mofa.go.jp,*
*Official Website: www.kh.emb-japan.go.jp*

# សេចក្តីណែនាំនៃការដាក់ពាក្យប្រឡងចម្រៀងណូដូជីម៉ាន់ឆ្នាំ២០២៥

**កម្មវិធីប្រឡងចម្រៀងណូដូជីម៉ាន់**

កាលបរិច្ឆេទ៖

- ✧ បើកទទួលពាក្យ៖ ថ្ងៃសុក្រ ទី២ ខែឧសភា តាមអនឡាញ
- ✧ បិទទទួលពាក្យ៖ ថ្ងៃអាទិត្យ ទី១ ខែមិថុនា
- ✧ លទ្ធផលវគ្គជម្រុះ៖ នឹងប្រកាសនៅថ្ងៃសុក្រ ទី២០ ខែមិថុនា
- ✧ វគ្គផ្តាច់ព្រ័ត្រ៖ ថ្ងៃអាទិត្យ ទី១៣ ខែកក្កដា ឆ្នាំ២០២៥ ម៉ោង ១៥:០០-១៧:៣០(អាចកែប្រែ) នៅសាលអង្គរ-គីហ្សូណា CJCC

ការប្រឡងវគ្គផ្តាច់ព្រ័ត្រ នឹងរៀបចំឡើងនៅCJCC ក្នុងឱកាសពិធីបុណ្យផ្កាយ (តាណាបាតា) ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។

- ➢ ស្វាគមន៍បេក្ខជនដែលមានសញ្ជាតិខ្មែរចូលរួមប្រឡងចម្រៀងណូដូជីម៉ាន់២០២៥។ បេក្ខជនអាចប្រឡងចម្រៀងទោល ឬ ប្រឡងជាក្រុម។

**ការដាក់ពាក្យសម្រាប់វគ្គជម្រុះ**

- ➢ បេក្ខជនត្រូវបំពេញគ្រប់ចំនុចដែលតម្រូវក្នុង Microsoft Form (https://forms.office.com/r/4GMt7CnDQW) (ពេលដាក់ពាក្យ ត្រូវតែភ្ជាប់លីងវីដេអូចម្រៀងរបស់ខ្លួន) ឱ្យបានត្រឹមថ្ងៃទី១ ខែមិថុនា។
- ➢ លទ្ធផលបេក្ខជនជាប់វគ្គជម្រុះ ដើម្បីចូលរួមការប្រឡងចម្រៀងណូដូជីម៉ាន់២០២៥ វគ្គផ្តាច់ព្រ័ត្រ នឹងត្រូវប្រកាសនៅថ្ងៃទី២០ ខែមិថុនា នៅលើគេហទំព័រ និងហ្វេសប៊ុកស្ថានទូតជប៉ុន។

ដំណើរការនៃវគ្គផ្តាច់ព្រ័ត្រ

- បេក្ខជនដែលចូលរួមប្រឡងវគ្គផ្តាច់ព្រ័ត្រ ត្រូវត្រៀមភ្លេងសម្រាប់ច្រៀងនៅថ្ងៃប្រឡងដោយខ្លួនឯង ហើយត្រូវផ្ញើមកកាន់ស្ថានទូតជាមុន ត្រឹមថ្ងៃចន្ទ ទី៣០ ខែមិថុនា។ ការប្រឡងចម្រៀងលើកនេះ មិនមានម៉ាស៊ីនខារ៉ាអូខេដែលអាចមើលឃើញអក្សរចម្រៀងទេ ដូច្នេះបេក្ខជនត្រូវទន្ទេញចាំបទចម្រៀង ឬត្រៀមណោតទំនុកច្រៀងដោយខ្លួនឯង ហើយច្រៀងលើឆាកតែម្តង។

- បេក្ខជនចូលរួមប្រឡងវគ្គផ្តាច់ព្រ័ត្រ តម្រូវមកកាន់ទីតាំងដើម្បីសម នៅសាលអង្គរ-គីហ្សូណា នៅម៉ោង១៣:៣០ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។
  ពេលវេលាសម ១៣:៣០- ១៤:៣០
  ពេលវេលាប្រឡងចម្រៀង ១៥:០០ -១៧:៣០
  * បញ្ជាក់ម៉ោងខាងលើអាចកែប្រែ។

ព័ត៌មានលម្អិត

- សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន
- ទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២២)
- អាសយដ្ឋានអ៊ីម៉េល៖ info.jpn@pp.mofa.go.jp